ashm

KHMER

# ព័ត៌មានសង្ខេបអំពី

# ជំងឺរលាកថ្លើមប្រភេទ C

*ប័ណ្ណព័ត៌មាននេះគឺសំរាប់អ្នកដែលបានទទួលលទ្ធផលតេស្តវិជ្ជមាន ថាមានអង្គបដិបក្ខជំងឺរលាកថ្លើមប្រភេទ C និងសំរាប់អ្នកដែលចង់ដឹងថែមទៀតអំពីជំងឺរលាកថ្លើមប្រភេទ C ។*

*លទ្ធផលតេស្តវិជ្ជមានមានន័យថា លោកអ្នកមានវីរុសជំងឺរលាកថ្លើមប្រភេទ C ។ លទ្ធផលនេះអាចធ្វើឲ្យលោកអ្នកតក់ស្លុត ហើយលោកអ្នកអាចមានសំណួរដែលលោកអ្នកត្រូវការចម្លើយ។*

មនុស្សម្នាក់ក្នុងចំណោមបួននាក់ដែលបានឆ្លងជំងឺរលាកថ្លើមប្រភេទ C នឹងកំចាត់មេរោគនេះចេញអស់ពីក្នុងខ្លួនដោយខ្លួនឯង។ វេជ្ជបណ្ឌិតលោកអ្នកអាចបញ្ជាឲ្យធ្វើតេស្តថែមទៀត ដើម្បីឲ្យដឹងថា តើលោកអ្នកស្ថិតនៅក្នុងចំណោមអ្នកទាំងនោះដែរឬទេ។ បើតេស្តបន្ថែមទៀតបង្ហាញឲ្យដឹងថា លោកអ្នកមានជំងឺរលាកថ្លើមប្រភេទ C នោះ វេជ្ជបណ្ឌិតលោកអ្នកអាចផ្តល់ជូនលោកអ្នកនូវព័ត៌មានបន្ថែមទៀត។ អង្គការទាំងឡាយដែលរាយឈ្មោះនៅខាងខ្នងប័ណ្ណព័ត៌មាននេះ អាចផ្តល់ជូនព័ត៌មានបន្ថែមនិងជំនួយ។

## ▶ តើជំងឺរលាកថ្លើមប្រភេទ C ជាអ្វីទៅ?

ជំងឺរលាកថ្លើមប្រភេទ C គឺជាជំងឺឆ្លងដោយវីរុសដែលចម្លងតាមឈាម ដែលអាចបំផ្លាញថ្លើមរបស់លោកអ្នក។ ជំងឺរលាកថ្លើមប្រភេទ C អាចក្លាយជាជំងឺរ៉ាំរ៉ៃ (រយៈពេលយូរ)។ លោកអ្នកអាចមានជំងឺនេះរយៈពេលច្រើនឆ្នាំមកហើយ ដោយពុំមានជួបប្រទះនឹងរោគសញ្ញាណាឡើយ។ យ៉ាងណាមិញ រោគសញ្ញាទូទៅទាំងឡាយមានរួមទាំងការអស់កម្លាំងល្ហិតល្ហៃ ចង្អោរ ឈឺចាប់នៅខាងក្រោមឆ្អឹងជំនី និងធ្វើទុក្ខនៅពេលបរិភោគអាហារដែលមានជាតិខ្លាញ់និងសុរា។ មិនដូចគ្នានឹងវីរុសនៃជំងឺរលាកថ្លើមប្រភេទផ្សេងទៀតទេ ជាធម្មតាជំងឺរលាកថ្លើមប្រភេទ C មិនបណ្តាលឲ្យលោកអ្នកធ្លាក់ខ្លួនឈឺឡើយនៅ ពេលដែលលោកអ្នកកើតមានវីរុសនេះជាលើកដំបូងនោះ។ មនុស្សជាច្រើនប្រហែលជាមិនដឹងថាខ្លួនកើតមានជំងឺនេះទៀតផង ទោះជាក្រោយពីកើតមានវីរុសនេះរយៈពេលជាច្រើនឆ្នាំមកហើយក៏ដោយ។ ប្រភេទចំបងនៃជំងឺរលាកថ្លើមប្រភេទ C មានយ៉ាងតិចក៏ 6 ដែរ ដែលហៅថាគំរូហ្សែន (genotypes) (មានលេខ 1, 2, 3, 4 ជាដើម) ហើយទាំងអស់នេះមានលក្ខណៈខុសៗគ្នាបន្តិច។

## ▶ តើលោកអ្នកអាចកើតជំងឺរលាកថ្លើមប្រភេទ C តាមរបៀបណា?

ជំងឺរលាកថ្លើមប្រភេទ C ឆ្លងតាមរយៈការប៉ះពាល់ឈាមនឹងឈាម។ មនុស្សភាគច្រើននៅក្នុងប្រទេសអូស្ត្រាលីនិងប្រទេសញូវហ្ស៊ីឡង់ ដែលមានជំងឺរលាកថ្លើមប្រភេទ C បានឆ្លងជំងឺនេះតាមរយៈការប្រើគ្រឿងសម្ភារៈចាក់ថ្នាំរួមគ្នា។ ការឆ្លងរោគក៏អាចកើតមានតាមរយៈការសាក់រាងកាយឬចោះរន្ធលើរាងកាយដែលគ្មានការរម្ងាប់មេរោគផងដែរ ដោយសារតែការចាក់នឹងម្ជុល ឬដោយសារការចាក់បញ្ចូលឈាម ឬ សារធាតុមានឈាម នៅក្នុងប្រទេសអូស្ត្រាលី មុនឆ្នាំ 1990 ។ ជំងឺរលាកថ្លើមប្រភេទ C ក៏អាចឆ្លងតាមរយៈការព្យាបាលឬការចាក់ថ្នាំបង្ការរោគដោយគ្រឿងសម្ភារៈមិនរម្ងាប់មេរោគ នៅក្នុងប្រទេសឯទៀតផងដែរ។ ការឆ្លងពីម្តាយទៅទារកគឺមានលទ្ធភាពតិចតួច។ លទ្ធភាពនៃការឆ្លងជំងឺរលាកថ្លើមប្រភេទ C ក្នុងអំឡុងការរួមរក្ស មានក៏វិតតិចតួចណាស់។ ជំងឺនេះមិនអាចឆ្លងតាមរយៈការប្រើប្រដាប់ប្រដារក្នុងផ្ទះរួមគ្នា ដូចជាពែងទឹកឬចាន ឬតាមរយៈការបរិភោគអាហារជាមួយគ្នានោះឡើយ។

## ▶ ការព្យាបាល

ការព្យាបាលមានគោលបំណងធ្វើឲ្យលោកអ្នកជាសះស្បើយពីជំងឺរលាកថ្លើមប្រភេទ C និងកាត់បន្ថយការខូចខាតថ្លើមលោកអ្នកឲ្យដល់កំរិតទាបបំផុត។ មិនមែនមនុស្សគ្រប់រូបត្រូវការការព្យាបាលឡើយ ព្រោះជាញឹកញាប់ ជំងឺរលាកថ្លើមប្រភេទ C មានសភាពមិនសូវធ្ងន់ធ្ងរទេ ហើយនឹងមិនប៉ះពាល់ដល់សុខភាពក្នុងរយៈពេលយូរឡើយ។ ការព្យាបាលជំងឺរលាកថ្លើមប្រភេទ C ដែលមានប្រសិទ្ធភាពបំផុតគឺការប្រើថ្នាំ pegylated interferon និង ribavirin គួបផ្សំគ្នា។ ការព្យាបាលជំងឺរលាកថ្លើមប្រភេទ C មានការរីកចំរើនយ៉ាងលឿននៅក្នុងពេលពីរបីឆ្នាំកន្លងមកនេះ ហើយចំនួនប្រហែល **80%** នៃ អ្នកដែលមានគំរូហ្សែនខ្លះនៃជំងឺថ្លើមនេះ និងចំនួនប្រហែល **50%** ដល់ **60%** នៃអ្នកទាំងអស់ដែលទទួលការព្យាបាលតាមវិធីគ្រាសព្វថ្ងៃ ពុំមានវីរុសនេះតទៅទៀតទេ។

ការព្យាបាលចំពោះគំរូហ្សែនខ្លះមានប្រសិទ្ធភាពច្រើនជាងគំរូហ្សែនផ្សេងទៀត។ នេះមានន័យថា មនុស្សជាច្រើនដែលមានជំងឺរលាកថ្លើមប្រភេទ C អាចបំបាត់វីរុសនេះចេញបាន ហើយពុំមានរោគសញ្ញាទៀតឡើយ។ គេប្រើថ្នាំ Interferon ដោយចាក់នៅក្រោមស្បែក និងលេបថ្នាំគ្រាប់ ribavirin។ ជាធម្មតា ការព្យាបាលមានរយៈពេលពី 6 ទៅ 12 ខែ។ ការឆែកពិនិត្យជាប្រក្រតីដោយវេជ្ជបណ្ឌិតឬអ្នកឯកទេសរបស់លោកអ្នក គឺជាការសំខាន់ចាំបាច់ក្នុងអំឡុងពេលព្យាបាលលោកអ្នក ដើម្បីតាមពិនិត្យការរីកចំរើនរបស់លោកអ្នក និងឆ្លើយតបទៅនឹងសំណួរណាមួយដែលលោកអ្នកអាចមាន

## ▶ ការពិនិត្យតាមដានសុខភាពលោកអ្នក

ដើម្បីស្វែងយល់របៀបដែលរាងកាយលោកអ្នកកំពុងទប់ទល់នឹងជំងឺរលាកថ្លើមប្រភេទ C លោកអ្នកត្រូវពិនិត្យតាមដានសុខភាពលោកអ្នក។ ទង្វើនេះអាចជួយក្នុងការសំរេចថាតើត្រូវចាប់ផ្តើមការព្យាបាលឬទេ ឬពេលណាទៅដែលត្រូវចាប់ផ្តើមការព្យាបាលនោះ។ ការតាមពិនិត្យជាប្រក្រតីនៃសុខភាពលោកអ្នកអាចជាប់ទាក់ទងនឹងការពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតក្នុងតំបន់ ឬអ្នកឯកទេសរបស់លោកអ្នក នៅឯមន្ទីរព្យាបាលថ្លើមឬជំងឺរលាកថ្លើម ឬក៏គួបផ្សំទាំងអស់នេះ។ ជាការសំខាន់បំផុតក្នុងការរក្សាការបរិភោគចំណីអាហារផ្តល់សុខភាពល្អ បញ្ឈប់ឬរឹតត្បិតការសេពសុរា និងហាត់ប្រាណជាប្រក្រតី។ នៅពេលដែលអ្នកណាមួយបានកើតជំងឺរលាកថ្លើមប្រភេទ C ហើយនោះ ជាធម្មតាការធ្វើតេស្តអង្គបដិបក្ខជំងឺរលាកថ្លើមប្រភេទ C នឹងផ្តល់លទ្ធផលវិជ្ជមាន ទោះជានៅក្រោយពីខ្លួនលោកអ្នកពុំមានវីរុសនេះតទៅទៀតក្តី ឬ ក្រោយពីការព្យាបាលដោយជោគជ័យក៏ដោយ។ ការធ្វើតេស្តមួយចំនួនត្រូវបានប្រើដើម្បីកំណត់ថា តើលោកអ្នកលែង កើតមានជំងឺរលាកថ្លើមប្រភេទ C ហើយឬនៅ (ដែលមានន័យថា លោកអ្នកពុំមានមេរោគតទៅទៀត ហើយវីរុសនេះ មិនបំផ្លាញថ្លើមលោកអ្នកតទៅទៀតទេ)។

## ▶ ការធ្វើតេស្ត

ការធ្វើតេស្តមុខងារថ្លើម ពិនិត្យមើលថាតើថ្លើមលោកអ្នកកំពុងបំពេញមុខងារយ៉ាងណាដែរ។ ការធ្វើតេស្តមួយក្នុងចំណោមតេស្តទាំងនេះមានឈ្មោះថា តេស្តរកមើលកំរិតសារធាតុ ALT (alanine aminotransferase) ។ សារធាតុនេះប្រាប់អំពីការខូចខាតថ្លើមនៅគ្រាសព្វថ្ងៃ។ សារធាតុនេះអាចឡើងចុះនៅក្នុងពេលមួយរយៈកាល ដោយសារតែមូលហេតុច្រើន ដោយមានរួមទាំងការសេពសុរា ការប្រើគ្រឿងញៀនឯទៀត ឬបើរាងកាយលោកអ្នកកំពុងប្រយុទ្ធតទល់នឹងរោគមួយទៀត។ សារធាតុនេះក៏អាចឡើងចុះផងដែរ ដោយសារតែជាលទ្ធផលនៃជំងឺរលាកថ្លើមប្រភេទ C ។

បើកំរិតសារធាតុ ALT លោកអ្នកឡើងនៅពេលមួយគ្រាឬច្រើនគ្រា វេជ្ជបណ្ឌិតលោកអ្នកអាចធ្វើតេស្ត PCR (ប្រតិកម្មអង់ហ្ស៊ីម polymerase តៗគ្នា) ដើម្បីកំណត់ថា តើលោកអ្នកបានបំបាត់វីរុសជំងឺរលាកថ្លើមប្រភេទ C អស់ហើយឬនៅ ឬថាតើវីរុសនេះនៅមាននៅឡើយឬទេ។ លោកអ្នកក៏អាចធ្វើតេស្តគំរូហ្សែនផងដែរ ដែលប្រាប់អំពីប្រភេទនៃវីរុសដែលលោកអ្នកមាន និងធ្វើតេស្តបន្ទុកវីរុស ដែលវាស់វែងបរិមាណវីរុសនៅក្នុងប្រព័ន្ធរាងកាយលោកអ្នក។ តេស្តគំរូហ្សែន និងបន្ទុកវីរុសផ្តល់នូវការចង្អុលបង្ហាញនូវលទ្ធផលនៃការព្យាបាល។ គេនឹងធ្វើតេស្ត PCR សាឡើងវិញនៅពេលមួយ ក្រោយពីការព្យាបាល ដើម្បីកំណត់ថា តើលោកអ្នកលែងមានវីរុសជំងឺរលាកថ្លើមប្រភេទ C តទៅទៀតឬទេ។

## ▶ វេជ្ជបណ្ឌិតលោកអ្នក

លោកអ្នកអាចពិភាក្សាជាមួយវេជ្ជបណ្ឌិតលោកអ្នកអំពីជំងឺរលាកថ្លើមប្រភេទ C ទៅតាមលក្ខណៈផ្ទាល់ខ្លួននិងលាក់ការសម្ងាត់។ នៅក្នុងរដ្ឋ NSW, ACT និងរដ្ឋ Victoria វេជ្ជបណ្ឌិតខ្លះមានការអនុញ្ញាតដើម្បីចេញវេជ្ជបញ្ជាឲ្យប្រើថ្នាំប្រឆាំងវីរុស នៅក្នុងកិច្ចសហការជាមួយអ្នកឯកទេស នៅឯមន្ទីរពេទ្យ ឬមន្ទីរព្យាបាលថ្លើមសាធារណៈ។ អង្គការទាំងឡាយដែលមានរាយឈ្មោះនៅលើប័ណ្ណនេះ អាចជួយលោកអ្នកនិងវេជ្ជបណ្ឌិតលោកអ្នក ក្នុងការរកមើលសេវាព្យាបាលជំងឺរលាកថ្លើមប្រភេទ C ។

## ▶ ការលាក់ការសម្ងាត់

នៅក្នុងកាលៈទេសៈភាគច្រើន លោកអ្នកមិនចាំបាច់ប្រាប់អ្នកណាមួយថា លោកអ្នកមានជំងឺរលាកថ្លើមប្រភេទ C ឡើយ។ យ៉ាងណាមិញ លោកអ្នកមានតម្រូវការផ្នែកច្បាប់ក្នុងការជំរាបប្រាប់កាកបាទក្រហម អំពីស្ថានភាពជំងឺរលាកថ្លើមប្រភេទ C របស់លោកអ្នក បើលោកអ្នកធ្វើអំណោយឈាម ហើយដូចគ្នានេះដែរ លោកអ្នកត្រូវប្រាប់កងកម្លាំងការពារជាតិអូស្ត្រាលី អំពីស្ថានភាពជំងឺរលាកថ្លើមប្រភេទ C របស់លោកអ្នក បើលោកអ្នកដាក់ពាក្យសុំចូលបំរើការក្នុង កងកម្លាំងនេះ។ បើលោកអ្នកជាបុគ្គលិកថែទាំសុខភាព ហើយមានជំងឺរលាកថ្លើមប្រភេទ C នោះ លោកអ្នកមិនត្រូវអនុវត្តកិច្ចការណាដែលអាចចម្លងមេរោគនេះឡើយ។

## ▶ ជនដែលលោកអ្នកអាចពិភាក្សាជាមួយ

បើលោកអ្នកមានជំងឺរលាកថ្លើមប្រភេទ C ហើយមានបំណងពិភាក្សាជាមួយអ្នកណាមួយអំពីជំងឺនេះ លោកអ្នកអាចទូរស័ព្ទទៅកាន់ក្រុមប្រឹក្សារដ្ឋឬដែនដីនៃជំងឺរលាកថ្លើម ក្នុងតំបន់លោកអ្នក។ ក្រុមប្រឹក្សាជំងឺរលាកថ្លើម ផ្តល់ព័ត៌មាននិងសេវាមួយចំនួន ដោយមានរួមទាំងការពិគ្រោះយោបល់លាក់ការសម្ងាត់ និងការបញ្ជូនទៅកាន់សេវាសុខភាពផ្សេងទៀត បើចាំបាច់។

បើលោកអ្នកមានបំណងពិភាក្សាជាភាសាលោកអ្នក ជាមួយសេវាណាមួយក្នុងចំណោមសេវាទាំងនេះ លោកអ្នកអាចទូរស័ព្ទទៅកាន់អ្នកបកប្រែភាសានៃសេវាបកប្រែភាសា **(Translating and Interpreting Service [TIS])** តាមទូរស័ព្ទលេខ **131 450** (បង់ថ្លៃទូរស័ព្ទក្នុងតំបន់)។ ប្រាប់អ្នកឆ្លើយទូរស័ព្ទថាលោកអ្នកត្រូវការអ្នកបកប្រែភាសា ហើយនៅពេលដែលគេតភ្ជាប់ទូរស័ព្ទជាមួយអ្នកបកប្រែភាសាហើយនោះ សូមប្រាប់អ្នកបកប្រែឲ្យទូរស័ព្ទទៅលេខដែលលោកអ្នកចង់ទាក់ទង។ បន្ទាប់មក លោកអ្នកនឹងអាចនិយាយទៅកាន់សេវាដែលលោកអ្នកត្រូវការ តាមរយៈអ្នកបកប្រែភាសា។

---

**Australian Hepatitis Council**
Tel: 02 6232 4257 (metro)
Help line: 1300 301 383 (regional)
Web: www.acthepc.org

**ACT Hepatitis C Council**
Tel: 02 6257 2911
Help line: 1300 301 383
Web: www.acthepc.org

**Hepatitis C Council of New South Wales**
Tel: 02 9332 1853 (metro)
Help line: 1800 803 990 (regional)
Web: www.hepatitisc.org.au

**Northern Territory AIDS & Hepatitis Council**
Tel: 08 8941 1711 (metro)
Info, support & referral:1800 880 899 (regional)
Web: www.ntahc.org.au

**Hepatitis C Council of Queensland**
Tel: 07 3236 0612 (metro)
Info line: 1800 648 491 (regional)
Web: www.hepatitisc.asn.au

**Hepatitis C Council of South Australia**
Tel: 08 8362 8443 (metro)
Help line: 1800 021 133 (regional)
Web: www.hepccouncilsa.asn.au

**Tasmanian Council on AIDS, Hepatitis and Related Diseases (TASCAHRD)**
Tel: 03 6234 1242 (metro)
Info line: 1800 005 900 (regional)
Web: www.tascahrd.org.au

**Hepatitis C Council of Victoria**
Tel: 03 9380 4644 (metro)
Help line: 1800 703 003 (regional)
Web: www.hepcvic.org.au

**Hepatitis Council of Western Australia**
Info & support: 08 9328 8538 (metro)
Info & support: 1800 800 070 (regional)
Web: www.hepatitiswa.com.au

This fact sheet is produced by the:
**Australasian Society for HIV Medicine Inc**
Locked Mail Bag 5057 Darlinghurst NSW 1300
Tel: 02 8204 0700
Fax: 02 9212 2671
Email: ashm@ashm.org.au

ABN 48 264 545 457

© Australasian Society for HIV Medicine 2006
ISBN 1 920773 35 5

Currently available in a State & Territory specific format and 8 community languages:
Arabic, Chinese, Greek, Indonesian, Italian, Khmer, Spanish, Vietnamese.

**Funded by the Australian Government, Department of Health and Ageing.**

Print more copies from:
**www.ashm.org.au/resources/publications/hepc-factsheet**